

# ការផ្លាស់ប្តូរគោលនយោបាយចុះឈ្មោះចូលរៀន

## ព័ត៌មានសម្រាប់គ្រួសារ

## ហេតុអ្វីជ្រើសរើសការអប់រំសាធារណៈ?

ប្រព័ន្ធអប់រំសាធារណៈនៃរដ្ឋ NSW ផ្តល់ឱ្យសិស្សទាំងអស់នូវការអប់រំលំដាប់ពិភពលោក ដោយរៀបចំកុមារនាពេលបច្ចុប្បន្នឱ្យទទួលបានជោគជ័យ និងកសាងសហគមន៍ឱ្យកាន់តែប្រសើរឡើងសម្រាប់អនាគត។ ជាមួយនឹងការផ្តល់ជូនការអប់រំពេញលេញ ប្រកបដោយគុណភាពខ្ពស់ និងឱកាសនានាសម្រាប់សកម្មភាពក្រៅកម្មវិធីសិក្សាដែលគ្មានគូប្រជែងក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា សិល្បៈ កីឡា និងលើសពីនេះ សាលារៀនរដ្ឋដែលផ្សេងពីគ្នា ហើយមានលក្ខណៈរួមបញ្ចូលរបស់យើង គាំទ្រសិស្សគ្រប់រូបឱ្យឈានដល់សក្តានុពលពេញលេញរបស់ពួកគេ។

## តើគោលនយោបាយចុះឈ្មោះចូលរៀនគឺជាអ្វី?

គោលនយោបាយចុះឈ្មោះចូលរៀន ជួយសាលារៀនឱ្យបំពេញកាតព្វកិច្ចរបស់ពួកគេក្រោមច្បាប់អប់រំ ឆ្នាំ 1990 (Education Act 1990) ដោយធានាថាសិស្សទាំងអស់មានលទ្ធភាពចូលរៀននៅសាលារៀនរដ្ឋក្នុងមូលដ្ឋានរបស់ពួកគេ។ គោលនយោបាយនេះក៏ផ្តល់ព័ត៌មានច្បាស់លាស់ផងដែរដល់បុគ្គលិក និងសហគមន៍អំពីរបៀបដែលការចុះឈ្មោះចូលរៀនត្រូវបានដោះស្រាយនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW។

## ហេតុអ្វីបានជាគោលនយោបាយផ្លាស់ប្តូរ?

ក្រសួងអប់រំរដ្ឋ NSW បានពិគ្រោះជាមួយដៃគូអប់រំ ក្រុមសហគមន៍ និងក្រុមអ្នកដឹកនាំសាលា ស្តីពីគោលនយោបាយចុះឈ្មោះចូលរៀនបច្ចុប្បន្ន។ យើងបានទទួលមតិកែលម្អជាច្រើនអំពីសារៈសំខាន់នៃការដោះស្រាយឧបសគ្គនានាដែលគ្រួសារជួបប្រទះនៅពេលព្យាយាមចុះឈ្មោះនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW។ គោលនយោបាយចុះឈ្មោះចូលរៀនដែលបានធ្វើបច្ចុប្បន្នភាព ដោះស្រាយឧបសគ្គទាំងនេះ ហើយសម្របតាមការប្តេជ្ញាចិត្តរបស់ក្រសួងក្នុងការកសាង និងទ្រទ្រង់ប្រព័ន្ធសាលារៀនសាធារណៈប្រកបដោយសមធម៌ និងអាចចូលប្រើប្រាស់បាន។

## តើមានការផ្លាស់ប្តូរអ្វីខ្លះ?

ការផ្លាស់ប្តូរខាងក្រោមនឹងអនុវត្តចំពោះការចុះឈ្មោះចូលរៀនទាំងអស់ដែលចាប់ផ្តើមនៅត្រីមាសទី 1 ក្នុងឆ្នាំ 2025។

### អ្នកស្នាក់នៅបណ្តោះអាសន្ន

សិស្សទាំងអស់ដែលកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន ឥឡូវនេះនឹងអាចចុះឈ្មោះនៅសាលារៀនក្នុងមូលដ្ឋានរបស់ពួកគេ ដោយផ្អែកលើអាសយដ្ឋានលំនៅដ្ឋានរបស់ពួកគេ។

ថ្លៃចុះឈ្មោះនឹងត្រូវបានលើកលែងសម្រាប់គ្រួសារនានាដែលជាអ្នកកាន់ទិដ្ឋាការកង្វះជំនាញបណ្តោះអាសន្នក្នុងតំបន់ភូមិភាគ (ថ្នាក់រង 482) ពោលគឺអ្នកដែលរស់នៅក្រៅទីក្រុងស៊ីដនី និងក្រុង Wollongong។

### លក្ខណៈវិនិច្ឆ័យដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់ការចុះឈ្មោះពីក្រៅមូលដ្ឋាន

សាលារៀនរដ្ឋក្នុងរដ្ឋ NSW មានតំបន់ចុះឈ្មោះក្នុងមូលដ្ឋានជាក់លាក់។ តំបន់ទទួលយកសិស្សដែលបានជ្រើសរើសត្រូវបានកំណត់ដោយក្រសួង។ សាលារៀនទាំងនេះធានាថាមានកន្លែងគ្រប់គ្រាន់សម្រាប់សិស្សដែលរស់នៅក្នុងតំបន់ចុះឈ្មោះក្នុងមូលដ្ឋានរបស់ពួកគេ។ អ្នកអាចដាក់ពាក្យសុំចុះឈ្មោះកូនរបស់អ្នកនៅក្រៅតំបន់ដែលបានជ្រើសរើសថាជា 'ការចុះឈ្មោះពីក្រៅមូលដ្ឋាន' ប្រសិនបើមានកន្លែងផ្តល់ជូន។

លក្ខណៈវិនិច្ឆ័យដែលបានធ្វើបច្ចុប្បន្នភាព ផ្តល់អាទិភាពដល់ការចុះឈ្មោះពីក្រៅមូលដ្ឋានសម្រាប់បងប្អូនបង្កើតរបស់សិស្សដែលបានចុះឈ្មោះបច្ចុប្បន្ន ដោយផ្តល់អាទិភាពដល់បងប្អូនបង្កើតរបស់សិស្សដែលបានចុះឈ្មោះក្នុងថ្នាក់គាំទ្រនៅសាលារៀនជាមួយសិស្សទូទៅភាគច្រើនដែលមានសិទ្ធិទទួល។

នៅក្រោមលក្ខណៈវិនិច្ឆ័យដែលបានធ្វើបច្ចុប្បន្នភាព សាលារៀនក៏អាចពិចារណាលើការចុះឈ្មោះពីក្រៅមូលដ្ឋានសម្រាប់កូនៗរបស់ពួកបុគ្គលិកសាលាផងដែរ។

## សំណួរដែលគេតែងសួរជាញឹកញាប់

### តើការផ្លាស់ប្តូរទាំងនេះអនុវត្តចំពោះកូនរបស់ខ្ញុំទេ?

ការផ្លាស់ប្តូរចំពោះការចុះឈ្មោះនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW ទាក់ទងនឹងអ្នកប្រសិនបើ៖

- កូនរបស់អ្នកមានអាយុចូលរៀន ហើយកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន ឬ
- កូនរបស់អ្នកមានអាយុចូលរៀន ហើយមានបងប្អូនបង្កើតម្នាក់ដែលបច្ចុប្បន្នបានចុះឈ្មោះនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW ផ្សេងគ្នា ហើយអ្នកចង់ឱ្យពួកគេចូលរៀននៅសាលារៀនដូចគ្នា។ លទ្ធភាពរបស់សាលារៀនក្នុងការទទួលយកការចុះឈ្មោះរបស់កូនអ្នក គឺអាស្រ័យលើសមត្ថភាព និងលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលរបស់ពួកគេ។
- អ្នកគឺជាបុគ្គលិកនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW នៅតំបន់ទទួលយកសិស្សដែលបានជ្រើសរើសរបស់កូនអ្នក។ សមត្ថភាពរបស់សាលារៀនក្នុងការទទួលយកការចុះឈ្មោះរបស់កូនអ្នក គឺអាស្រ័យលើសមត្ថភាព និងលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលរបស់ពួកគេ។

### តើគ្រប់សាលារៀនទាំងអស់នឹងត្រូវបានតម្រូវឱ្យអនុវត្តការផ្លាស់ប្តូរទាំងនេះទេ?

សាលារៀនទាំងអស់ត្រូវបានតម្រូវឱ្យអនុវត្តការផ្លាស់ប្តូរទាំងនេះ សម្រាប់សិស្សកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន។

សាលារៀនភាគច្រើន អាស្រ័យលើសមត្ថភាពរបស់ពួកគេ ត្រូវបានតម្រូវឱ្យអនុវត្តការផ្លាស់ប្តូរទាំងនេះសម្រាប់ការចុះឈ្មោះពីក្រៅមូលដ្ឋានសម្រាប់សិស្សដែលកំពុងចុះឈ្មោះសម្រាប់ត្រីមាសទី 1 ក្នុងឆ្នាំ 2025។

ការផ្លាស់ប្តូរគោលនយោបាយចុះឈ្មោះចូលរៀនសម្រាប់សិស្សស្នាក់នៅបណ្តោះអាសន្ន និងសិស្សពីក្រៅមូលដ្ឋាននឹងមិនប៉ះពាល់ដល់តម្រូវការសិទ្ធិទទួលសម្រាប់ទីកន្លែងរៀន ឬកម្មវិធីឯកទេសទេ។ សាលារៀនដែលមានលក្ខណៈវិនិច្ឆ័យសិទ្ធិទទួល រួមមានសាលាជ្រើសរើសសិស្សមានទេពកោសល្យពេញលេញ សាលារៀនសម្រាប់គោលបំណងជាក់លាក់ (schools for specific purposes (SSPs)) សាលាអប់រំពីចម្ងាយ និងសាលារៀនដែលមានថ្នាក់ ឬកម្មវិធីតម្រូវសិទ្ធិទទួលជាក់លាក់ (ឧទាហរណ៍ ថ្នាក់សិស្សមានទេពកោសល្យកីឡាឯកទេស និង/ឬ សិល្បៈដែលមើលឃើញតាមសមត្ថភាព) នឹងបន្តអនុវត្តតាមដំណើរការចុះឈ្មោះបច្ចុប្បន្នរបស់ពួកគេ។

សាលារៀនសម្រាប់សិស្សភេទតែមួយ ត្រូវតែអនុវត្តការផ្លាស់ប្តូរទាំងនេះ ដរាបណាកុមារដែលកំពុងចុះឈ្មោះបំពេញតាមលក្ខខណ្ឌតម្រូវរបស់សាលារៀនសម្រាប់ភេទនោះ។ សូមទាក់ទងសាលារៀនដែលពាក់ព័ន្ធ ដើម្បីសួរនាំពីការផ្លាស់ប្តូរទាំងនេះអនុវត្តបែបណាដែរ។

### ប្រសិនបើកូនរបស់ខ្ញុំជាបងប្អូនបង្កើតរបស់សិស្សដែលបានចុះឈ្មោះបច្ចុប្បន្ន តើពាក្យសុំចុះឈ្មោះពីក្រៅមូលដ្ឋានរបស់ពួកគេនឹងត្រូវបានទទួលយកដោយស្វ័យប្រវត្តិដែរឬទេ?

ការផ្លាស់ប្តូរទាំងនេះមិនធានាចំពោះការចុះឈ្មោះកូនរបស់អ្នកនៅសាលារៀនរដ្ឋពីក្រៅមូលដ្ឋានដូចគ្នា ជាមួយបងប្អូនបង្កើតរបស់ពួកគេទេ។ សាលារៀននឹងផ្តល់អាទិភាពដល់ការចុះឈ្មោះពីក្រៅមូលដ្ឋានសម្រាប់បងប្អូនបង្កើតរបស់សិស្សដែលបានចុះឈ្មោះបច្ចុប្បន្ន ប្រសិនបើអាចធ្វើទៅបាន ប៉ុន្តែការទទួលយកពាក្យសុំរបស់ពួកគេអាចអាស្រ័យលើសមត្ថភាពរបស់សាលារៀន។ សូមទាក់ទងសាលារៀនដែលពាក់ព័ន្ធសម្រាប់ព័ត៌មានបន្ថែម។

### តើនេះមានន័យថា មានតែបងប្អូនបង្កើតនឹងត្រូវបានទទួលយកជាការចុះឈ្មោះពីក្រៅមូលដ្ឋានចាប់ពីពេលនេះទៅឬ?

ទេ អ្នកនៅតែអាចដាក់ពាក្យសុំចុះឈ្មោះកូនរបស់អ្នកនៅសាលារដ្ឋណាមួយបាន ប្រសិនបើកុមារមានសិទ្ធិចូលរៀនសាលានោះ ហើយសាលារៀនអាចផ្តល់កន្លែងរៀនសម្រាប់កុមារនោះ។ ឥឡូវនេះ សាលារៀនត្រូវតែផ្តល់អាទិភាព និងពិចារណាលើពាក្យសុំនានាទល់នឹងលក្ខណៈវិនិច្ឆ័យនៃការចុះឈ្មោះពីក្រៅមូលដ្ឋានដែលបានធ្វើបច្ចុប្បន្នភាព (រួមទាំងលក្ខណៈវិនិច្ឆ័យទាក់ទងនឹងតម្រូវការសុខុមាលភាពសិស្ស) ដែលផ្តល់អាទិភាពដល់បងប្អូនបង្កើតរបស់សិស្សដែលបានចុះឈ្មោះបច្ចុប្បន្ន និងពិចារណាលើកូនៗរបស់ពួកបុគ្គលិកសាលា។

### តើការចុះឈ្មោះពីក្រៅមូលដ្ឋានសម្រាប់កូនៗរបស់ពួកបុគ្គលិកសាលានឹងត្រូវបានទទួលយកដោយស្វ័យប្រវត្តិឬ?

ទេ។ សាលារៀននឹងផ្តល់អាទិភាពលើពាក្យសុំពីក្រៅមូលដ្ឋានសម្រាប់បងប្អូនបង្កើតរបស់សិស្សដែលបានចុះឈ្មោះបច្ចុប្បន្ន ហើយបន្ទាប់មកអាចពិចារណាលើការចុះឈ្មោះពីក្រៅមូលដ្ឋានសម្រាប់កូនៗរបស់ពួកបុគ្គលិកសាលា។ ប្រសិនបើអ្នកជាសមាជិកបុគ្គលិកសាលា ការទទួលយកកូនៗរបស់អ្នកអាចអាស្រ័យលើសមត្ថភាពរបស់សាលារៀន។ លក្ខណៈវិនិច្ឆ័យនៃការចុះឈ្មោះពីក្រៅមូលដ្ឋានដែលបានធ្វើបច្ចុប្បន្នភាព នឹងមិនប៉ះពាល់ដល់សិទ្ធិទទួលរបស់កូនអ្នកក្នុងការចុះឈ្មោះនៅសាលារៀនក្នុងមូលដ្ឋានរបស់ពួកគេទេ។

## ការចុះឈ្មោះសិស្សកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន

**កូនរបស់ខ្ញុំកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន។ ពីមុន ខ្ញុំបានដាក់ពាក្យសុំចុះឈ្មោះពួកគេនៅសាលារៀនក្នុងមូលដ្ឋានរបស់ពួកគេ ប៉ុន្តែពាក្យសុំត្រូវបានបដិសេធ។ តើខ្ញុំអាចដាក់ពាក្យសុំរបស់កូនខ្ញុំម្តងទៀតបានទេ?**

អ្នកអាចដាក់ពាក្យសុំចុះឈ្មោះរបស់អ្នកឡើងវិញបាន ប្រសិនបើកូនរបស់អ្នកកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន ហើយពាក្យសុំពីមុនរបស់ពួកគេទៅកាន់សាលារៀនក្នុងមូលដ្ឋានរបស់អ្នកត្រូវបានបដិសេធ។ សូមអនុវត្តតាមជំហានដែលបានរៀបរាប់នៅផ្នែកខាងក្រោម "តើខ្ញុំផ្លាស់ប្តូរកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំសម្រាប់ឆ្នាំ 2025 យ៉ាងដូចម្តេច?"

**កូនរបស់ខ្ញុំកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន ហើយខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំរួចហើយនៅសាលារៀនមួយសម្រាប់ឆ្នាំ 2025។ តើខ្ញុំអាចផ្លាស់ប្តូរកន្លែងដែលខ្ញុំចុះឈ្មោះកូនរបស់ខ្ញុំបានទេ?**

ប្រសិនបើកូនរបស់អ្នកកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន ហើយបានចុះឈ្មោះចូលរៀនរួចហើយនៅសាលារៀនមួយសម្រាប់ឆ្នាំ 2025 អ្នកអាចដាក់ពាក្យដើម្បីផ្លាស់ប្តូរកន្លែងដែលពួកគេកំពុងចុះឈ្មោះបច្ចុប្បន្ន។ សូមអនុវត្តតាមជំហានដែលបានរៀបរាប់នៅផ្នែកខាងក្រោម "តើខ្ញុំផ្លាស់ប្តូរកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំសម្រាប់ឆ្នាំ 2025 យ៉ាងដូចម្តេច?"

**តើខ្ញុំផ្លាស់ប្ដូរកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំសម្រាប់ឆ្នាំ 2025 យ៉ាងដូចម្ដេច?**

ឪពុកម្ដាយ ឬអ្នកថែទាំសិស្សដែលកាន់ទិដ្ឋាការស្នាក់នៅបណ្ដោះអាសន្នត្រូវអនុវត្តតាមជំហានទាំងនេះ ដើម្បីផ្លាស់ប្ដូរការចុះឈ្មោះនៅសាលារៀនក្នុងមូលដ្ឋានរបស់ពួកគេ៖

1. ទាក់ទងក្រុមកម្មវិធីអ្នកស្នាក់នៅបណ្ដោះអាសន្នតាមទូរសព្ទលេខ 1300 300 229 (ជម្រើសទី 1) ឬតាមរយៈអ៊ីមែល tempvisa@det.nsw.edu.au ដើម្បីស្នើសុំការផ្លាស់ប្ដូរសាលារៀនសម្រាប់កូនរបស់អ្នក។ ក្រុមកម្មវិធីអ្នកស្នាក់នៅបណ្ដោះអាសន្ននឹងជូនដំណឹងអ្នក នៅពេលពួកគេបានបញ្ចប់ការផ្ទេរសាលារៀនសម្រាប់កូនរបស់អ្នក។
2. ទាក់ទងសាលារៀនក្នុងមូលដ្ឋានរបស់អ្នក ដើម្បីចុះឈ្មោះកូនរបស់អ្នក។ សាលារៀននឹងផ្ដល់ឱ្យអ្នកនូវទម្រង់ពាក្យសុំជាក្រដាសដែលអ្នកនឹងត្រូវបំពេញដើម្បីចុះឈ្មោះ។ ស្វែងរកព័ត៌មានទំនាក់ទំនងសាលារៀនក្នុងតំបន់របស់អ្នកនៅតាមគេហទំព័រ education.nsw.gov.au/find-a-public-school

**កូនរបស់ខ្ញុំកាន់ទិដ្ឋាការស្នាក់នៅបណ្ដោះអាសន្ន ក្រៅពីទិដ្ឋាការ 482។ តើខ្ញុំត្រូវបង់ថ្លៃចុះឈ្មោះទេ?**

ថ្លៃដាក់ពាក្យអ្នកស្នាក់នៅបណ្ដោះអាសន្ន និងថ្លៃសិក្សាដើម្បីចុះឈ្មោះចូលរៀននៅសាលារៀនរដ្ឋ ជាទូទៅត្រូវបានគណនាដោយប្រើថ្នាក់រងទិដ្ឋាការដែលសិស្សកាន់។ សម្រាប់ព័ត៌មានលម្អិតអំពីថ្លៃសេវាដែលអនុវត្តចំពោះទិដ្ឋាការថ្នាក់រងរបស់អ្នក សូមចូលទៅកាន់គេហទំព័រ DE International៖ deinternational.nsw.edu.au/study-options/study-programs/temporary-residents។ ប្រសិនបើអ្នកនៅតែមិនប្រាកដថាតើការលើកលែងថ្លៃសេវាត្រូវបានអនុវត្តចំពោះអ្នកឬអត់ អ្នកអាចទាក់ទងក្រុមកម្មវិធីអ្នកស្នាក់នៅបណ្ដោះអាសន្នតាមរយៈ tempvisa@det.nsw.edu.au

## ការចុះឈ្មោះបងប្អូនបង្កើតពីក្រៅមូលដ្ឋាន

**ខ្ញុំបានដាក់ពាក្យសុំចុះឈ្មោះកូនរបស់ខ្ញុំនៅសាលាដែលបងប្អូនបង្កើតរបស់ពួកគេចូលរៀន ប៉ុន្តែពាក្យសុំរបស់ពួកគេត្រូវបានបដិសេធ។ តើខ្ញុំអាចដាក់ពាក្យសុំរបស់កូនខ្ញុំម្ដងទៀតបានទេ?**

ប្រសិនបើអ្នកបានដាក់ពាក្យសុំចុះឈ្មោះកូនរបស់អ្នកនៅសាលារៀនក្រៅមូលដ្ឋានរបស់បងប្អូនបង្កើតពួកគេ ហើយពាក្យសុំត្រូវបានបដិសេធ សូមអនុវត្តតាមជំហានដែលមានចែងនៅផ្នែកខាងក្រោម "តើខ្ញុំផ្លាស់ប្ដូរកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំសម្រាប់ឆ្នាំ 2025 យ៉ាងដូចម្ដេច?"

**ខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំនៅសាលារៀនមួយសម្រាប់ឆ្នាំ 2025 ប៉ុន្តែបងប្អូនបង្កើតរបស់ពួកគេបានចុះឈ្មោះនៅសាលារៀនក្រៅមូលដ្ឋានផ្សេង។ តើខ្ញុំអាចដាក់ពាក្យសុំផ្លាស់ប្ដូរកន្លែងដែលពួកគេចុះឈ្មោះបានទេ?**

ប្រសិនបើអ្នកចង់ផ្លាស់ប្ដូរសាលារៀនដែលកូនរបស់អ្នកបានចុះឈ្មោះសម្រាប់ឆ្នាំ 2025 ទៅសាលារៀនក្រៅមូលដ្ឋានដូចគ្នាដែលបងប្អូនបង្កើតរបស់ពួកគេកំពុងសិក្សា សូមអនុវត្តតាមជំហានដែលមានចែងនៅផ្នែកខាងក្រោម "តើខ្ញុំផ្លាស់ប្ដូរកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំសម្រាប់ឆ្នាំ 2025 យ៉ាងដូចម្ដេច?"

**តើខ្ញុំផ្លាស់ប្ដូរកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំសម្រាប់ឆ្នាំ 2025 យ៉ាងដូចម្ដេច?**

ឪពុកម្ដាយ ឬអ្នកថែទាំដែលចង់ចុះឈ្មោះកូនរបស់ពួកគេនៅសាលារៀនក្រៅមូលដ្ឋានដូចគ្នានឹងបងប្អូនបង្កើតរបស់ពួកគេ ត្រូវអនុវត្តតាមជំហានទាំងនេះដើម្បីផ្លាស់ប្ដូរការចុះឈ្មោះរបស់ពួកគេ៖

### ពាក្យសុំចុះឈ្មោះតាមអនឡាញ

1. ចូលទៅកាន់គេហទំព័ររបស់សាលារៀនដែលអ្នកចង់ដាក់ពាក្យសុំចុះបន្ទាប់មកចុចលើការចុះឈ្មោះក្នុងជម្រើសបញ្ជី។
2. នៅលើទំព័របណ្ដាញចុះឈ្មោះ នៅក្រោមចំណងជើងរបៀបចុះឈ្មោះ សូមចុចលើតំណភ្ជាប់ទៅកាន់ពាក្យសុំចុះឈ្មោះតាមអនឡាញ។
3. នៅពេលដែលអ្នកបានដាក់ពាក្យសុំចុះឈ្មោះរបស់អ្នកហើយ សាលារៀនអាចផ្ដល់ឱ្យអ្នកនូវកន្លែងរៀនមួយដែលអ្នកនឹងត្រូវទទួលយកក្នុងរយៈពេល 14 ថ្ងៃ។
4. ប្រសិនបើពាក្យសុំរបស់អ្នកត្រូវបានទទួលយក សូមទាក់ទងសាលារៀនដែលកូនរបស់អ្នកបានចុះឈ្មោះពីមុនសម្រាប់ឆ្នាំ 2025 ដើម្បីដកចេញការចុះឈ្មោះនោះ។

### ទម្រង់ពាក្យសុំជាក្រដាស

1. ទាក់ទងសាលារៀនរបស់បងប្អូនបង្កើតរបស់កូនអ្នក ដើម្បីរកមើលថាតើពួកគេអាចផ្ដល់កន្លែងរៀនសម្រាប់កូនរបស់អ្នកបានដែរឬទេ។
2. ប្រសិនបើសាលារៀនអាចផ្ដល់កន្លែងរៀនសម្រាប់កូនរបស់អ្នក សូមបំពេញទម្រង់ពាក្យសុំជាក្រដាសថ្មីមួយ ដែលសាលារៀនអាចផ្ដល់ឱ្យ។
3. នៅពេលដែលអ្នកបានដាក់ពាក្យសុំជាក្រដាសរបស់អ្នកដើម្បីចុះឈ្មោះហើយ សាលារៀនអាចផ្ដល់ឱ្យអ្នកនូវកន្លែងរៀនមួយដែលអ្នកនឹងត្រូវទទួលយកក្នុងរយៈពេល 14 ថ្ងៃ។
4. ប្រសិនបើពាក្យសុំរបស់អ្នកត្រូវបានទទួលយក សូមទាក់ទងសាលារៀនដែលកូនរបស់អ្នកបានចុះឈ្មោះពីមុនសម្រាប់ឆ្នាំ 2025 ដើម្បីដកចេញការចុះឈ្មោះនោះ។

**ខ្ញុំបានដាក់ពាក្យសុំការបញ្ចេញចំណាប់អារម្មណ៍ (Expression of Interest (EOI)) សម្រាប់ការធ្វើអន្តរកាលពីថ្នាក់ទី 6 ទៅថ្នាក់ទី 7 ក្នុងឆ្នាំ 2025។ តើខ្ញុំអាចផ្លាស់ប្ដូរកន្លែងដែលខ្ញុំចុះឈ្មោះកូនរបស់ខ្ញុំបានទេ?**

EOI សម្រាប់ការធ្វើអន្តរកាលពីថ្នាក់ទី 6 ទៅថ្នាក់ទី 7 បានបិទហើយ ដូច្នេះឪពុកម្ដាយ និងអ្នកថែទាំមិនអាចធ្វើការផ្លាស់ប្ដូរបញ្ជីចំណង់ចំណូលចិត្តសាលារបស់ពួកគេសម្រាប់ឆ្នាំ 2025 ទៀតទេ។

ប្រសិនបើអ្នកចង់ផ្លាស់ប្ដូរសាលារៀនដែលអ្នកបានចុះឈ្មោះកូនរបស់អ្នកសម្រាប់ឆ្នាំ 2025 ទៅសាលារៀនក្រៅមូលដ្ឋានដូចគ្នាដែលបងប្អូនបង្កើតរបស់ពួកគេកំពុងចូលរៀន អ្នកគួរតែអនុវត្តតាមជំហានខាងក្រោម៖

### ពាក្យសុំចុះឈ្មោះតាមអនឡាញ

1. ចូលទៅកាន់គេហទំព័ររបស់សាលារៀនដែលអ្នកចង់ដាក់ពាក្យសុំចុះឈ្មោះ បន្ទាប់មកចុចលើការចុះឈ្មោះក្នុងជម្រើសបញ្ជី។
2. នៅលើទំព័របណ្ដាញចុះឈ្មោះ នៅក្រោមចំណងជើងរបៀបចុះឈ្មោះ ចុចលើតំណភ្ជាប់ទៅកាន់ពាក្យសុំចុះឈ្មោះតាមអនឡាញ។
3. នៅពេលដែលអ្នកបានដាក់ពាក្យសុំចុះឈ្មោះរបស់អ្នកហើយ សាលារៀនអាចផ្ដល់ឱ្យអ្នកនូវកន្លែងរៀនមួយដែលអ្នកនឹងត្រូវទទួលយកក្នុងរយៈពេល 14 ថ្ងៃ។
4. ប្រសិនបើពាក្យសុំរបស់អ្នកត្រូវបានទទួលយក សូមទាក់ទងសាលារៀនដែលកូនរបស់អ្នកបានចុះឈ្មោះពីមុនសម្រាប់ឆ្នាំ 2025 ដើម្បីដកចេញការចុះឈ្មោះនោះ។

### ទម្រង់ពាក្យសុំជាក្រដាស

1. ទាក់ទងសាលារៀនរបស់បងប្អូនបង្កើតរបស់កូនអ្នក ដើម្បីរកមើលថាតើពួកគេអាចផ្តល់កន្លែងរៀនសម្រាប់កូនរបស់អ្នកបានដែរឬទេ។ ស្វែងរកទំនាក់ទំនងរបស់សាលារៀននៅតាមគេហទំព័រ៖ education.nsw.gov.au/find-a-public-school។
2. ប្រសិនបើសាលារៀនអាចផ្តល់កន្លែងរៀនសម្រាប់កូនរបស់អ្នក សូមបំពេញទម្រង់ពាក្យសុំជាក្រដាសថ្មីមួយ ដែលសាលារៀនអាចផ្តល់ឱ្យ។
3. នៅពេលដែលអ្នកបានដាក់ពាក្យសុំជាក្រដាសរបស់អ្នកដើម្បីចុះឈ្មោះហើយ សាលារៀនអាចផ្តល់ឱ្យអ្នកនូវកន្លែងរៀនមួយដែលអ្នកនឹងត្រូវទទួលយកក្នុងរយៈពេល 14 ថ្ងៃ ឬឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។
4. ប្រសិនបើពាក្យសុំរបស់អ្នកត្រូវបានទទួលយក ហើយអ្នកបានទទួលយកការផ្តល់ជូន EOI របស់អ្នករួចហើយ សូមទាក់ទងសាលារៀនដោយផ្ទាល់ដើម្បីដកចេញការចុះឈ្មោះនោះ។

## ការចុះឈ្មោះកុមារក្រៅមូលដ្ឋានរបស់ពួកបុគ្គលិកសាលា

**ខ្ញុំបានដាក់ពាក្យសុំចុះឈ្មោះកូនរបស់ខ្ញុំនៅសាលារៀនដែលខ្ញុំធ្វើការ ប៉ុន្តែពាក្យសុំរបស់ពួកគេត្រូវបានបដិសេធ។ តើខ្ញុំអាចដាក់ពាក្យសុំចុះឈ្មោះរបស់កូនខ្ញុំម្តងទៀតបានទេ?**

ប្រសិនបើអ្នកបានដាក់ពាក្យសុំចុះឈ្មោះកូនរបស់អ្នកនៅសាលារៀនដែលអ្នកធ្វើការ ហើយពាក្យសុំត្រូវបានបដិសេធ អ្នកអាចដាក់ពាក្យសុំម្តងទៀតបាន។ ដើម្បីធ្វើដូច្នេះ សូមអនុវត្តតាមជំហានដែលបានរៀបរាប់នៅផ្នែកខាងលើក្រោមចំណងជើង "តើខ្ញុំផ្លាស់ប្តូរកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំសម្រាប់ឆ្នាំ 2025 យ៉ាងដូចម្តេច?"។

## តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមនៅឯណា?

**សម្រាប់ការសាកសួរអំពីការចុះឈ្មោះ សូមនិយាយទៅកាន់សាលារៀនដែលអ្នកពេញចិត្ត។ ស្វែងរកព័ត៌មានទំនាក់ទំនងសាលារៀនរបស់អ្នកនៅតាមគេហទំព័រ៖ education.nsw.gov.au/find-a-public-school**

**សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបចុះឈ្មោះនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW៖ education.nsw.gov.au/enrolment**

**សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបចុះឈ្មោះនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW ជាអ្នកស្នាក់នៅបណ្តោះអាសន្ន៖ https://www.deinternational.nsw.edu.au/**

**សម្រាប់ការសាកសួរអំពីការចុះឈ្មោះទូទៅ សូមទាក់ទងការិយាល័យកណ្តាលនៃក្រសួងអប់រំ៖ 1300 679 332**

**សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ**

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ដើម្បីជួយអ្នកក្នុងការទាក់ទងមកសាលារៀន ឬក្រសួងអប់រំ សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ តាមលេខ 13 14 50 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ សូមប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។